**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃ គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០២ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការប្រឆាំងការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៦១៩ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ



www.pheakdeylaw.com

# សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃ គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម សរសេរជាអក្សរកាត់ថា (គ.ជ.ប.ទ) ។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចខាងក្រោម៖

- កំណត់អំពីបេសកកម្ម និងរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន គ.ជ.ប.ទ
- រៀបចំមុខងារ និងភារកិច្ចរបស់អង្គភាពនានាដែលចំណុះលេខាធិការដ្ឋាន គ.ជ.ប.ទ
- ធានាគុណភាព និងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងាររបស់លេខាធិការដ្ឋាន គ.ជ.ប.ទ។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើលេខាធិការដ្ឋាន និង អង្គភាពនានាចំណុះលេខាធិការដ្ឋាន គ.ជ.ប.ទ ។

## ជំពូកទី២
## តួនាទី និងភារកិច្ច

**មាត្រា៤.-**

លេខាធិការដ្ឋាន គ.ជ.ប.ទ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- ធានានិរន្តរភាព និងដំណើរការការងាររដ្ឋបាលរបស់ គ.ជ.ប.ទ
- រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព របស់ គ.ជ.ប.ទ
- លើកគម្រោងថវិកាប្រចាំឆ្នាំរបស់ គ.ជ.ប.ទ
- គ្រប់គ្រងហិរញ្ញវត្ថុ គណនេយ្យ ចំណូល ចំណាយ ចលនទ្រព្យ អចលនទ្រព្យ របស់ គ.ជ.ប.ទ
- គ្រប់គ្រងមន្ត្រី បុគ្គលិក លេខាធិការដ្ឋាន គ.ជ.ប.ទ
- លើកសំណើជ្រើសរើស តែងតាំង ផ្ទេរភារកិច្ច លើកសរសើរ ជូនរង្វាន់ តម្លើងឋានៈ ដាក់វិន័យ ឬបញ្ចប់តំណែង មន្ត្រី បុគ្គលិក លេខាធិការដ្ឋាន
- ប្រមូលព័ត៌មាន អំពីចំនួននិងទីតាំងកន្លែងឃុំឃាំង ចំនួននិងស្ថានភាពជនដែលត្រូវបានដកហូត



www.pheakdeylaw.com

សេរីភាព ជូន គ.ជ.ប.ទ

- រៀបចំកម្មវិធី ទស្សនកិច្ចត្រួតពិនិត្យទីកន្លែងឃុំឃាំង ហេដ្ឋារចនាសម្ព័ន្ធ និងឧបករណ៍នៃទីកន្លែងឃុំឃាំង និងការប្រព្រឹត្តមកលើជនដែលត្រូវបានដកហូតសេរីភាពនៅតាមទីកន្លែងនោះ ទាំងកន្លែងឯកជន និងទាំងកន្លែងសាធារណៈ ជូន គ.ជ.ប.ទ
- រៀបចំនិងលើកអនុសាសន៍ជូន គ.ជ.ប.ទ ដើម្បីកែលម្អការប្រព្រឹត្ត និងលក្ខខណ្ឌនៃជនដែលត្រូវបានដកហូតសេរីភាព ដើម្បីបង្ការទារុណកម្ម ដោយផ្អែកលើបញ្ញត្តិច្បាប់ជាតិ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធរបស់ជាតិ និងអង្គការសហប្រជាជាតិ នៅតាមកន្លែងឃុំឃាំង
- លើកសំណើនិងសេចក្តីសង្កេត ពាក់ព័ន្ធនឹងច្បាប់ដែលកំពុងមានជាធរមាន និងសេចក្តីព្រាងច្បាប់ជាតិនានា ជូន គ.ជ.ប.ទ
- រៀបចំកម្មវិធីបណ្តុះបណ្តាល វិក្រឹត្យការ ដល់មន្ត្រីលេខាធិការដ្ឋាន និងក្រុមគោលដៅដែលអនុវត្តការងារដកហូតសេរីភាព អំពីច្បាប់ជាតិ គោលនយោបាយជាតិ អនុសញ្ញាប្រឆាំងទារុណកម្ម និងពិធីសារបន្ថែម
- រៀបចំកម្មវិធីអប់រំ ផ្សព្វផ្សាយ អំពីបទបញ្ញត្តិច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តជាតិ អនុសញ្ញានិងពិធីសារបន្ថែម ពាក់ព័ន្ធនឹងការប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប
- រៀបចំសន្និបាត កិច្ចប្រជុំ និងសិក្ខាសាលា របស់ គ.ជ.ប.ទ
- រៀបចំរបាយការណ៍ជាតិស្តីពីការអនុវត្តអនុសញ្ញាប្រឆាំងទារុណកម្ម និងពិធីសារបន្ថែម តាមកាលកំណត់ ជូន គ.ជ.ប.ទ
- ទំនាក់ទំនងជាមួយអនុគណៈកម្មាធិការបង្ការ របស់អង្គការសហប្រជាជាតិជូន គ.ជ.ប.ទ ដើម្បីផ្តល់ព័ត៌មាន និងជួបប្រជុំ
- ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយព័ត៌មាននានារបស់ គ.ជ.ប.ទ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ស្តីពីលទ្ធផលការងាររបស់ គ.ជ.ប.ទ ដែលទទួលបាន និងលើកទិសដៅបន្ត
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាន គ.ជ.ប.ទ ប្រគល់ជូន។

## ជំពូកទី៣
## រចនាសម្ព័ន្ធ

**មាត្រា៥.-**

លេខាធិការដ្ឋាន គ.ជ.ប.ទ ត្រូវដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន តាមការចាំបាច់ ។

ប្រធានលេខាធិការដ្ឋាន ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ និងអនុប្រធានត្រូវតែងតាំងដោយអនុក្រឹត្យ ។



www.pheakdeylaw.com

**មាត្រា៦.-**

លេខាធិការដ្ឋាន គ.ជ.ប.ទ មានរចនាសម្ព័ន្ធដូចខាងក្រោម ៖
- ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ
- ផ្នែកនីតិកម្ម និងជំនួយផ្នែកច្បាប់
- ផ្នែកបណ្តុះបណ្តាល និងផ្សព្វផ្សាយអប់រំ
- ផ្នែកទំនាក់ទំនង និងសហប្រតិបត្តិការ

អង្គការលេខ នៃលេខាធិការដ្ឋាន គ.ជ.ប.ទ ភ្ជាប់ជាឧបសម្ព័ន្ធ ១ នៃអនុក្រឹត្យនេះ ។

**មាត្រា៧.-**

ផ្នែកនីមួយៗ ត្រូវដឹកនាំដោយប្រធាន ០១ (មួយ) រូប តែងតាំងដោយអនុក្រឹត្យ និងអមដោយអនុប្រធានមួយចំនួន តែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

លេខាធិការដ្ឋាន គ.ជ.ប.ទ អាចមានការិយាល័យមួយចំនួនតាមការចាំបាច់ ។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា៨.-**

**ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ** មានភារកិច្ច ដូចខាងក្រោម ៖
- សហការជាមួយផ្នែកផ្សេងទៀត ដើម្បីរៀបចំផែនការសកម្មភាពការងារ របស់ គ.ជ.ប.ទ
- រៀបចំលិខិតបទដ្ឋាននានារបស់ គ.ជ.ប.ទ
- គ្រប់គ្រង និងចាត់ចែងឯកសាររដ្ឋបាលផ្សេងៗ របស់ គ.ជ.ប.ទ
- លើកគម្រោងផែនការ ហិរញ្ញវត្ថុ សម្ភារៈ កសុភារ មធ្យោបាយដឹកជញ្ជូន ចលនទ្រព្យ និងអចលនទ្រព្យ របស់ គ.ជ.ប.ទ
- គ្រប់គ្រង ចំណូល ចំណាយ ថវិកា និងផ្គត់ផ្គង់
- គ្រប់គ្រង ដឹកនាំ និងចាត់ចែងការងាររដ្ឋបាល បុគ្គលិក ផែនការ ស្ថិតិ និងសរុប
- លើកសំណើជ្រើសរើស តែងតាំង ផ្ទេរភារកិច្ច លើកសរសើរ ជូនរង្វាន់ តម្លើងឋានៈ ដាក់វិន័យ ឬបញ្ចប់តំណែង មន្ត្រី បុគ្គលិក លេខាធិការដ្ឋាន
- រៀបចំសិក្ខាសាលា ឬកិច្ចប្រជុំផ្សេងៗ របស់ គ.ជ.ប.ទ
- បូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ របស់គ.ជ.ប.ទ និងលើកទិសដៅបន្ត
- អនុវត្តភារកិច្ចផ្សេងៗ ទៀតដែលប្រធានលេខាធិការដ្ឋាន គ.ជ.ប.ទ ប្រគល់ជូន ។

**មាត្រា៩.-**

**ផ្នែកនីតិកម្ម និងជំនួយផ្នែកច្បាប់ មានភារកិច្ចដូចខាងក្រោម ៖**
- សិក្សាស្រាវជ្រាវ អំពីវិវឌ្ឍភាពច្បាប់ជាតិ អន្តរជាតិ ដែលកំពុងមានជាធរមាននៅកម្ពុជា ក៏ដូចជាបណ្តាប្រទេសជាហត្ថលេខីលើអនុសញ្ញា និងពិធីសារបន្ថែម របស់អង្គការសហប្រជាជាតិ



www.pheakdeylaw.com

- សិក្សា លើកសំណើ និងលើកសេចក្តីសង្កេត ពាក់ព័ន្ធនឹងច្បាប់ដែលកំពុងមានជាធរមាន និងសេចក្តីព្រាងច្បាប់ជាតិនានា ជូន គ.ជ.ប.ទ
- ទំនាក់ទំនង និងសម្របសម្រួល ប្រមូលព័ត៌មាន ចំនួនទីកន្លែងឃុំឃាំង ចំនួនជនដែលត្រូវបានដកហូតសេរីភាព ព្រមទាំងស្ថានភាព និងការប្រព្រឹត្តមកលើជនទាំងនោះ ជូន គ.ជ.ប.ទ
- រៀបចំកម្មវិធី និងចូលរួមទស្សនកិច្ចត្រួតពិនិត្យទីកន្លែងឃុំឃាំង ជូន គ.ជ.ប.ទ
- ទទួល ពិនិត្យ និងសិក្សាវាយតម្លៃពាក្យបណ្តឹង និងលើកយោបល់ឬសំណើ ជូន គ.ជ.ប.ទ
- សិក្សា ស្រាវជ្រាវ អំពីទារុណកម្មដែលប្រព្រឹត្តលើជនដែលត្រូវបានដកហូតសេរីភាព ដែលទទួលបានព័ត៌មានពីបណ្តាញសារព័ត៌មានផ្សេងៗ
- ប្រឹក្សាយោបល់ផ្នែកច្បាប់ ពាក់ព័ន្ធនឹងសិទ្ធិរួចផុតពីទារុណកម្ម របស់ជនដែលត្រូវបានដកហូតសេរីភាព
- លើកយោបល់ និងផ្តល់អនុសាសន៍ជូន គ.ជ.ប.ទ ក្នុងគោលបំណងកែលម្អការប្រព្រឹត្តមកលើ និងផ្តល់លក្ខខណ្ឌសមស្របសម្រាប់ជនដែលត្រូវបានដកហូតសេរីភាព
- បូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ របស់ផ្នែក និងលើកទិសដៅបន្ត
- អនុវត្តការកិច្ចផ្សេងៗទៀត ដែលប្រធានលេខាធិការដ្ឋាន គ.ជ.ប.ទ ប្រគល់ជូន ។

**មាត្រា១០.-**

**ផ្នែកបណ្តុះបណ្តាល និងផ្សព្វផ្សាយអប់រំ** មានភារកិច្ច ដូចខាងក្រោម ៖

- រៀបចំ ផែនការ ឧបករណ៍ សម្ភារៈ និងមេរៀន សម្រាប់អប់រំ បណ្តុះបណ្តាលអំពីបញ្ញត្តិច្បាប់ជាតិពាក់ព័ន្ធនឹងសិទ្ធិរួចផុតពីទារុណកម្ម អនុសញ្ញាប្រឆាំងទារុណកម្ម និងពិធីសារបន្ថែម
- រៀបចំ និងផ្តល់វគ្គបណ្តុះបណ្តាល ដល់មន្ត្រី បុគ្គលិក លេខាធិការដ្ឋាន និងក្រុមគោលដៅ ដែលអនុវត្តការងារដកហូតសេរីភាព
- រៀបចំ និងផ្តល់វិញ្ញាបនប័ត្រ ជូនសិក្ខាកាម ដែលបានបញ្ចប់វគ្គ
- សិក្សាស្រាវជ្រាវ រៀបចំ ចងក្រង ផលិត និងចែកផ្សាយ ឯកសារពាក់ព័ន្ធនឹងសិទ្ធិរួចផុតពីទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម របស់ជនដែលត្រូវបានដកហូតសេរីភាព ដូចដែលមានចែងក្នុងច្បាប់ជាតិ និងអនុសញ្ញាអន្តរជាតិ
- ផ្សព្វផ្សាយរាល់សកម្មភាពនានារបស់រាជរដ្ឋាភិបាល ក្នុងដំណើរការបំពេញកាតព្វកិច្ចជារដ្ឋភាគីនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងពិធីសារបន្ថែម
- បូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ របស់ផ្នែក និងលើកទិសដៅបន្ត
- អនុវត្តការកិច្ចផ្សេងៗទៀត ដែលប្រធានលេខាធិការដ្ឋាន គ.ជ.ប.ទ ប្រគល់ជូន ។

**មាត្រា១១.-**

**ផ្នែកទំនាក់ទំនង និងសហប្រតិបត្តិការ** មានភារកិច្ច ដូចខាងក្រោម ៖

- ទំនាក់ទំនង សហការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ គ្រឹះស្ថាន វិទ្យាស្ថានជាតិ ស្ថានទូត និងដៃគូអភិវឌ្ឍ នានា



www.pheakdeylaw.com

- រៀបចំផែនការទស្សនកិច្ចសិក្សា និងចូលរួមការពារបាយការណ៍ជាតិ ទាំងក្នុងនិងក្រៅប្រទេស
- រៀបចំកិច្ចព្រមព្រៀង ឬអនុស្សរណៈយោគយល់គ្នា រវាង គ.ជ.ប.ទ និង អង្គការ ស្ថាប័នជាតិ អន្តរជាតិ ជាដៃគូ
- សម្របសម្រួល ទំនាក់ទំនង ប្រមូលព័ត៌មានជាតិ និងអនុសាសន៍របស់គណៈកម្មាធិការប្រឆាំងទារុណកម្មរបស់អង្គការសហប្រជាជាតិ ដើម្បីរៀបចំសរសេរបាយការណ៍ជាតិ ជូន គ.ជ.ប.ទ
- ទំនាក់ទំនង និងសម្របសម្រួល ដំណើរទស្សនកិច្ចរបស់អនុគណៈកម្មាធិការបង្ការ និងអ្នករាយការណ៍ពិសេស ទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ
- បូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ របស់ផ្នែក និងលើកទិសដៅបន្ត
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធានលេខាធិការដ្ឋាន គ.ជ.ប.ទ ប្រគល់ជូន ។

## ជំពូកទី៤
## ក្របខ័ណ្ឌមន្ត្រី

**មាត្រា១២.-**

មន្ត្រីរាជការបំរើការងារនៅលេខាធិការដ្ឋាន គ.ជ.ប.ទ ជាមន្ត្រីដែលស្ថិតនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈ។

មន្ត្រីរាជការបំរើការងារនៅលេខាធិការដ្ឋាន គ.ជ.ប.ទ ត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ ។ ក្នុងករណីចាំបាច់ លេខាធិការដ្ឋានអាចស្នើសុំផ្ទេរមន្ត្រីជំនាញពីក្រសួង ស្ថាប័នដទៃ ឬអាចមានមន្ត្រីជាប់កិច្ចសន្យា ដើម្បីជួយបំពេញការងារ ។

**មាត្រា១៣.-**

មន្ត្រីរាជការនៃលេខាធិការដ្ឋាន គ.ជ.ប.ទ មានឯកសណ្ឋានសម្គាល់ដោយឡែក ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន គ.ជ.ប.ទ ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



www.pheakdeylaw.com

**មាត្រា១៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៣ កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កុម្ភៈ ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com

**ឧបសម្ព័ន្ធ១** នៃអនុក្រឹត្យលេខ...២៨.....អនក្រ.បក ចុះថ្ងៃទី...២៧......ខែ..កុម្ភៈ....ឆ្នាំ២០១៨

អង្គការលេខរបស់លេខាធិការដ្ឋាន

នៃគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ

អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម

(គ.ជ.ប.ទ)




www.pheakdeylaw.com